ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

លេខ/N°PTM2020034566 អពដ



# ប័ណ្ណពន្ធប៉ាតង់ ឆ្នាំ ២០២០
## អ្នកជាប់ពន្ធធំ

ឈ្មោះសហគ្រាស៖ ភី ភី អេស អ៊ី ស៊ី ឯ.ក
លេខអត្តសញ្ញាណកម្មសារពើពន្ធ៖ L001-901804753
ចុះបញ្ជីនៅ៖ អគ្គនាយកដ្ឋានពន្ធដារ ស្ថិតនៅក្រោមការគ្រប់គ្រង៖ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
ទ្រង់ទ្រាយសហគ្រាស៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
សកម្មភាពអាជីវកម្មចម្បង៖ រោងចក្រផលិតគ្រឿងភ្ជាប់នឹងសម្លៀកបំពាក់
អាសយដ្ឋានសហគ្រាស៖ #ឡូត៍លេខP២-១១២-B តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ផ្លូវជាតិលេខ៤ ភូមិបឹងធំទី៣ សង្កាត់បឹងធំ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ឈ្មោះម្ចាស់សហគ្រាស៖ S.E.C. ACCESSORIES LIMITED
តំណាងដោយ៖ CHAN WEI MAN សញ្ជាតិ៖ ចិន

# PATENT TAX 2020
## Large Taxpayer

Company's name : P P S E C COMPANY LIMITED
Tax Identification Number (TIN) : L001-901804753
Registered at : General Department of Taxation Under : Department of large Taxpayers
Main business activity(ies) : Manufacturing on garment accessories
Forms of business : Private limited company
Owner's name : S.E.C. ACCESSORIES LIMITED
Represented by : CHAN WEI MAN Nationality: Chinese

ទឹកប្រាក់ពន្ធប៉ាតង់ ២០២០
៣,០០០,០០០ រៀល
លេខ SN: 004979770

អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation
បោះពុម្ពនៅ / Printed at
ACLEDA Bank

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០
Phnom Penh,12 March 2020

សម្គាល់៖ ប័ណ្ណប៉ាតង់នេះត្រូវដាក់តាំង ឬព្យួរ នៅទីកន្លែងប្រកបអាជីវកម្ម
Note : This patent tax must be hanged or displayed at the company's office.

# ភារកិច្ចរបស់អាជីវកម្មដ្ឋាន

(ដកស្រង់ពីក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី ១៤-០៦-១៩៨៥)

**មាត្រា ១៣ ៖** អាជីវកម្មដ្ឋានមានភារកិច្ចដូចតទៅ ៖

ក- ប្រកាសឱ្យស្មោះត្រង់ ចំពោះអង្គការពន្ធដែលស្ថិតនៅកន្លែងប្រកបអាជីវកម្មយ៉ាងយឺតបំផុត ១០ ថ្ងៃ មុនពេលចាប់ផ្ដើមប្រកបអាជីវកម្ម។

ខ- ប្រកាសឱ្យអង្គការពន្ធដឹង អំពីស្ថានភាពអាជីវកម្មតាមគំរូ និង រយៈពេលដែលអង្គការពន្ធបានកំណត់។

គ- ប្រកាសឱ្យអង្គការពន្ធដឹង ក្នុងករណីមានការកែប្រែកិច្ចការប្រកបអាជីវកម្មដូចជា៖ ផ្លាស់ប្ដូរ, ប្ដូរទីកន្លែង, ប្ដូរមុខរបរ, ពង្រីកមុខរបរ។

ឃ- បង់ឱ្យគ្រប់ នូវចំនួនប្រាក់ពន្ធប៉ាតង់តាមរយៈពេលកំណត់របស់អង្គការពន្ធ។ ក្នុងករណីដែលមានការតវ៉ា អំពីចំនួនប្រាក់ពន្ធដែលត្រូវបង់ អាជីវករត្រូវតែបង់ឱ្យគ្រប់តាមចំនួន និងតាមកំណត់ពេលរបស់អង្គការពន្ធ ក្នុងពេលរង់ចាំការដោះស្រាយបណ្ដឹងតវ៉ា។

**មាត្រា ១៤ ៖** ក្រោយពេលបង់ពន្ធ អាជីវកម្មដ្ឋានត្រូវបានទទួលប័ណ្ណប៉ាតង់។ ប័ណ្ណប៉ាតង់នេះមានតម្លៃចំពោះអ្នកដែលមានឈ្មោះក្នុងប័ណ្ណប៉ាតង់តែប៉ុណ្ណោះ។

អាជីវករមិនអាចឱ្យខ្ចី ឬផ្ទេរឱ្យអ្នកដទៃដោយគ្មានការអនុញ្ញាតពីអង្គការពន្ធបានឡើយ។

នៅពេលឈប់ប្រកបអាជីវកម្ម អាជីវករត្រូវប្រគល់ប័ណ្ណប៉ាតង់ឱ្យអង្គការពន្ធវិញ។

**មាត្រា ១៥ ៖** អាជីវកម្មដ្ឋានអចល័តត្រូវព្យួរប័ណ្ណប៉ាតង់នៅមាត់ទ្វារចូលនៃអាគារលក់ដូរ រោងចក្ររោងជាងផលិត។

ប្រសិនបើទៅលក់ដូរនៅក្រៅកន្លែងដែលបានសុំប្រកបអាជីវកម្ម អាជីវករត្រូវសុំអង្គការពន្ធឱ្យចេញលិខិតបញ្ជាក់ថា៖ បានបង់ពន្ធប៉ាតង់ហើយ ដើម្បីនាំតាមខ្លួន។ លិខិតបញ្ជាក់នេះមានតម្លៃតែមួយដង ឬក្នុងរយៈពេលមួយមានកំណត់។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ...៥៥៦៦.....អពដ

L20200207001 | TD3407

ថ្ងៃសុក្រ ០៦ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០២០

**ជម្រាបជូន**

**លោក-លោកស្រីនាយក**

ឈ្មោះក្រុមហ៊ុន ÷ ភី ភី អេស អ៊ី ស៊ី ឯ.ក
ជាអក្សរឡាតាំង ÷ P P S E C COMPANY LIMITED
លេខអត្តសញ្ញាណកម្ម ÷ L001-901804753 ចុះបញ្ជីនៅ ÷ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
អាសយដ្ឋាន ÷ #ឡូត៍លេខP២-១១២-B តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ផ្លូវ ជាតិលេខ៤ ភូមិ បឹងធំទី៣ សង្កាត់បឹងធំ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

---

**កម្មវត្ថុ** ÷ ករណីសុំលើកលែងការផាកពិន័យ លើការបង់ពន្ធយឺតយ៉ាវ

**យោង** ÷
- ច្បាប់ស្តីពីសារពើពន្ធប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងធ្វើវិសោធនកម្មបន្តបន្ទាប់
- សេចក្តីជូនដំណឹងលេខ ៨៦៧២ អពដ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានពន្ធដារ
- លិខិតគ្មានលេខ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ភី ភី អេស អ៊ី ស៊ី ឯ.ក
- បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខ ០០៤២០៧០២៦ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ របស់ធនាគារអេស៊ីលីដា

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ អគ្គនាយកដ្ឋានពន្ធដារ សូមជម្រាបលោក-លោកស្រីនាយកក្រុមហ៊ុនជ្រាបថា ដោយកន្លងមកក្រុមហ៊ុនលោក-លោកស្រីបានបំពេញកាតព្វកិច្ចសារពើពន្ធដោយបានដាក់លិខិតប្រកាសប្រចាំខែ និងលិខិតប្រកាសប្រចាំឆ្នាំ និងបានបង់ប្រាក់ពន្ធទាន់ពេលវេលា ប៉ុន្តែនៅខែមេសា ឆ្នាំ២០១៩ ក្រុមហ៊ុនបានបង់ប្រាក់ពន្ធនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ ដែលមានបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខ ០០៤២០៧០២៦ ទទួលរងនូវប្រាក់ទោសទណ្ឌសរុបចំនួន ៨៣៧ ៨៤៥ រៀល ហើយក្រុមហ៊ុនក៏បានស្នើសុំលើកលែងប្រាក់ទោសទណ្ឌនេះ។

អគ្គនាយកដ្ឋានពន្ធដារបានពិនិត្យឃើញថា ក្រុមហ៊ុនពុំមានចេតនាគេចវេះពន្ធនោះឡើយ ដូចនេះត្រូវបានអនុញ្ញាតលើកលែងប្រាក់ទោសទណ្ឌសរុបចំនួន ៨៣៧ ៨៤៥ រៀល តាមការស្នើសុំរបស់ក្រុមហ៊ុនលោក-លោកស្រីនាយក។

សូមលោក-លោកស្រីនាយកក្រុមហ៊ុន ភី ភី អេស អ៊ី ស៊ី ឯ.ក ទទួលនូវការរាប់អាន ពីខ្ញុំ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

ចម្លងជូន ÷
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- (ដើម្បីមុខការ)
- ឯកសារ-កាលប្បវត្តិ